# ដំណោះស្រាយការបោះឆ្នោតសម្រាប់ប្រជាជនគ្រប់គ្នា

## បោះឆ្នោតតាមសំបុត្រ ៖ អ្វីដែលអ្នកត្រូវដឹង

ខោនធី Los Angeles បានរចនាឡើងវិញនូវសម្ភារៈបោះឆ្នោតតាមសំបុត្រ (VBM) ដើម្បីធ្វើឱ្យកាន់តែងាយស្រួលនិងស្រណុកក្នុងការបោះឆ្នោតតាមសំបុត្រ ។ ការបោះឆ្នោតសាកលនៅថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2018 នឹងជាលើកដំបូងដែលអ្នកបោះឆ្នោតតាមសំបុត្រ (VBM) នឹងទទួលបានសម្ភារៈដែលត្រូវបានរចនាឡើងវិញទាំងនេះ ។ នេះជាអ្វីដែលអ្នកត្រូវដឹង ៖

### សន្លឹកឆ្នោត និងស្រោមសំបុត្រថ្មី

- ធំជាងមុន
- ងាយស្រួលអានជាងមុន
- ងាយស្រួលបំពេញជាងមុន
- ងាយស្រួលយល់ជាងមុន

### សន្លឹកឆ្នោតជាពហុភាសា

យើងខ្ញុំផ្ដល់សន្លឹកឆ្នោតក្នុងភាសាចំនួន 12 ។

ទូរស័ព្ទមកការិយាល័យរបស់យើងខ្ញុំដើម្បីស្នើសុំសន្លឹកឆ្នោតពហុភាសារបស់អ្នក តាមរយៈ: លេខ **(800) 815-2666, ជម្រើស 3**

### ជម្រើសបញ្ជូនត្រឡប់វិញ

អ្នកនៅតែអាចបញ្ជូនត្រឡប់វិញដោយងាយស្រួលនូវសន្លឹកឆ្នោត VBM របស់អ្នកមកកាន់យើងខ្ញុំតាមរយៈ USPS ដោយភ្ជាប់តែមប្រៃសណីយ៍ដែលចាំបាច់ ។ បន្ថែមលើនេះ អ្នកអាចទម្លាក់វានៅទីតាំងបោះឆ្នោតណាមួយក៏បាន ឬទីតាំងទម្លាក់សន្លឹកឆ្នោតថ្មីណាមួយរបស់យើងខ្ញុំដែលស្ថិតនៅជិតៗ ។




សូមចូលទៅកាន់ LAvote.net ដើម្បីស្នើសុំសន្លឹកឆ្នោត VBM, ស្វែងរកទីតាំងទម្លាក់សន្លឹកឆ្នោត VBM ឬតាមដានសន្លឹកឆ្នោត VBM របស់អ្នក ។